# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2012, 15:05
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំរបស់ នួន ជា គាំទ្រ សំណើរបស់ អៀង សារី សុំស្តាប់សក្ខីកម្មរបស់ ហោ ណាំហុង និង គាត ឈន់**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Joshua ROSENSWEIG
Sofie HOGESTOL
Renee DE GEUS

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

១. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្ដី អៀង សារី បានដាក់សំណើសុំអង្គជំនុំជម្រះ សាលាដំបូងឲ្យកោះហៅ គាត ឈន់ និង ហោ ណាំហុង មកផ្ដល់សក្ខីកម្ម ដោយសារមានអង្គហេតុថ្មីៗចេញពីសវនាការ ("សំណើសុំរបស់ អៀង សារី")[១]។ នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានផ្ដល់ទឡ្ហីករណ៍នៅក្នុងចម្លើយតបរបស់ខ្លួនថា ទោះបីជាសក្ខីកម្មទាំងនេះអាចនាំដល់ការស្វែងរកការពិតក៏ដោយ ក៏វាពុំមែន "សំខាន់ជាចាំបាច់" សម្រាប់រឿង ក្ដីរបស់ អៀង សារី ឡើយ។ អាស្រ័យហេតុនេះ សក្ខីកម្មនេះអាច នៅក្នុងដំណាក់កាលក្រោយ តម្រូវឲ្យដកចេញដែល ប្រសិនបើសក្ខីកម្មនេះបង្ហាញថាពុំអាចទទួលបានក្នុងរយៈពេលមួយសមស្រប អនុលោមតាមវិធាន ៨៧(៣)(ខ)[២]។

២. នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១២ សហមេធាវីការពារក្ដី នួន ជា ("ក្រុមមេធាវីការពារក្ដី") បានដាក់ញត្តិគាំទ្រសំណើសុំរបស់ អៀង សារី ("ញត្តិគាំទ្រ")[៣] ដោយបានគាំទ្រការវិភាគរបស់ អៀង សារី លើភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់សាក្សីទាំងពីរនេះ ហើយក៏បានជម្រុញឲ្យអង្គជំនុំជម្រះពិចារណាថា ការមិនព្រមបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺជាការពិចារណាដែលពាក់ព័ន្ធដល់ការសម្រេចចិត្តក្នុងការកោះហៅសាក្សីមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នាពេលមុននោះដែលនោះជាអំពើខុសច្បាប់ គឺជាហេតុផលបន្ថែមទៀតគាំទ្រដល់ការកោះហៅសាក្សីទាំងពីររូបនេះមកចំពោះមុខអង្គជំនុំជម្រះ។ ញត្តិនេះក៏បានរិះគន់ ចំពោះភាពពុំប្រាកដប្រជារបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីលទ្ធភាពនៃការខកខានរបស់សាក្សីក្នុងការមកបង្ហាញខ្លួន ជាពិសេស ដែលវាផ្ទុយនឹងជំហរច្បាស់លាស់របស់គាត់នៅក្នុងដំណាក់កាលមុន[៤]។

---

[១] ឯកសារ **E-228**, 'សំណើរបស់ អៀង សារី សុំស្ដាប់សក្ខីកម្មរបស់ឯកឧត្ដម គាត ឈន់ និងឯកឧត្ដម ហោ ណាំហុង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង', ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, ERN 00846399-00846410 ('សំណើរបស់ អៀង សារី')។

[២] ឯកសារ **E-228/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះ 'សំណើរបស់ អៀង សារី សុំស្ដាប់សក្ខីកម្មរបស់ឯកឧត្ដម គាត ឈន់ និងឯកឧត្ដម ហោ ណាំហុង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង', ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ , ERN 0849279-0849279 ('ចម្លើយតបដំបូងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ')។

[៣] ឯកសារ **E-228/2**, 'ញត្តិគាំទ្រសំណើរបស់ អៀង សារី សុំស្ដាប់សក្ខីកម្មរបស់ ហោ ណាំហុង និងគាត ឈន់', ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១២, ERN 00853849-00853853 ('ញត្តិគាំទ្រ')។

[៤] ញត្តិគាំទ្រ, កថាខណ្ឌ ៥ ដល់ ៦។

៣. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបទៅនឹងញត្តិគាំទ្រនៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១២ ("ចម្លើយតបរបស់ ស.ព.អ")[៥]។ ស.ព.អ បានផ្តល់ទឡ្ហីករណ៍ថា (i) ញត្តិគាំទ្រនេះ "មិនទំនងបើនិយាយអំពីអានុភាពរបស់វា" ពីព្រោះញត្តិនេះពុំបានព្យាយាមបង្ហាញអំពីភាពពាក់ព័ន្ធនៃសាក្សីទាំងពីររូបទៅនឹងរឿងក្តី នួន ជា[៦]; (២) ការជ្រៀតជ្រែកខាងនយោបាយពុំពាក់ព័ន្ធនឹងបញ្ហាចោទថាតើសាក្សីទាំងពីររូបនេះត្រូវ ឬពុំត្រូវមកផ្តល់ សក្ខីកម្មឡើយ[៧]; និង (iii) ការយល់ឃើញរបស់ ស.ព.អ ពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះ នៅក្នុងពេលសវនាការ គឺមានលក្ខណៈខុសគ្នាយ៉ាងសមហេតុផលពីដំណាក់កាលស៊ើបសួរ ដោយសារភាពខុសគ្នានៅក្នុងបរិបទអង្គហេតុ និងអង្គច្បាប់[៨]។ ដូច្នេះ ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា ទឡ្ហីករណ៍ ទាំងនេះធ្វើឲ្យមានភាពយល់ច្រឡំ ពុំគួរឲ្យជឿ និងគួរត្រូវអង្គជំនុំជម្រះបដិសេធចោល។

៤. ចំណុចទីមួយ ស.ព.អ បានចោទប្រកាន់ថា ញត្តិគាំទ្រអាចនឹង "សមហេតុផលទៅបាន" វៀរលែងតែ បន្ថែមលើការបង្ហាញអំពីភាពពាក់ព័ន្ធដែលបានលើកឡើងដោយ អៀង សារី "មេធាវីការពារក្តីត្រូវបង្ហាញពីរបៀបដែលថា សក្ខីកម្មរបស់សាក្សីដែលបានស្នើសុំនោះ នឹងមានការពាក់ព័ន្ធទៅនឹងកូនក្តីរបស់ខ្លួន គឺ នួន ជា"[៩]។ ជាការពិត សំណើសុំរបស់ អៀង សារី បានបង្ហាញថា សាក្សីទាំងពីររូបធ្លាប់ជាកម្មាភិបាលជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្លាប់ធ្វើការប្រាស្រ័យទាក់ទងយ៉ាងទៀងទាត់ជាមួយ ប៉ុល ពត និងកម្មាភិបាលជាន់ខ្ពស់បំផុតផ្សេងទៀតនៅក្នុងជួរបក្ស។ ការរៀបរាប់ទាំងនេះត្រូវបានសរសេរឯកភាពយ៉ាងជាក់លាក់នៅក្នុងញត្តិគាំទ្រ[១០]។ ក្រុមមេធាវីការពារក្តីបានសន្មតថា ច្បាប់ពាក់ព័ន្ធនឹងភស្តុតាងបែបនេះទៅនឹងមេដឹកនាំបក្សមួយក្រុមតូច ដែលត្រូវបានចោទប្រកាន់ថាធ្លាប់បានធ្វើការរួមគ្នាឆ្ពោះទៅរកការអនុវត្តគោលនយោបាយបោសសម្អាតនៅពេញមួយ

---

[៥] ឯកសារ **E-228/3**, 'ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង 'ញត្តិគាំទ្ររបស់ នួន ជា លើសំណើសុំរបស់ អៀង សារី សុំស្តាប់សក្ខីកម្មរបស់ ហោ ណាំហុង និង គាត ឈន់', ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១២, ERN 0857214-0857214។

[៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៣ ដល់ ៧។

[៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨។

[៨] ចម្លើយតបសហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៩ ដល់ ១៣។

[៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៣។

[១០] ញត្តិគាំទ្រ, កថាខណ្ឌ ២។

របបនេះ អាចនឹងមានភាពច្បាស់លាស់[១១]។ ប្រសិនបើវាពុំច្បាស់ទេ នោះ យើងខ្ញុំសូមធ្វើការបញ្ជាក់បំភ្លឺដូចខាងក្រោម៖

៥. ឧទាហរណ៍ជាក់ស្តែង សំណើសុំរបស់ អៀង សារី បានពន្យល់ថា គាត ឈន់ អាចផ្តល់សក្ខីកម្មអំពី៖ តើបុគ្គលណានៅក្នុងរចនាសម្ព័ន្ធបក្សមានអំណាចគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើការចាប់ខ្លួន និងបោសសម្អាត; បុគ្គលណានៅក្រោមជនជាប់ចោទ ដែលទទួលខុសត្រូវដាច់ដោយឡែកលើការបង្កើត "ក្រឹត្យក្រម"; "ប្រព័ន្ធរាយការណ៍" នៅក្នុងក្រសួងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងការដឹងឮថា រដ្ឋមន្ត្រីក្រសួងនានា ទំនងជាមាន; និងចំណងទាក់ទងដោយផ្ទាល់រវាង ប៉ុល ពត និងបុគ្គលនានាដែលនៅក្រោមជនជាប់ចោទផ្ទាល់តែម្តង។ សំណើសុំរបស់ អៀង សារី បានបង្ហាញថា ហោ ណាំហុង អាចផ្តល់សក្ខីកម្មអំពី៖ តួនាទីរបស់ ប៉ង់ ដែលជាកម្មាភិបាលអន្តរការីរវាងគណៈកម្មាធិការមជ្ឈិម និង ស-២១ ដែល យោងតាមសំដី ឌុច ប៉ង់ នេះជាអ្នកនាំសារដោយផ្ទាល់រវាង ឌុច និង ប៉ុល ពត[១២]; ភាពស្វយ័តរបស់ ហោ ណាំហុង នៅក្នុងការកាន់កាប់គុកបឹងត្របែក ដែល នួន ជា ត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវលើគុកនេះ[១៣] និងទំនាក់ទំនងរវាងរដ្ឋមន្ត្រីក្រសួងនានា និងកម្មាភិបាលក្រោមបង្គាប់។

៦. ចំណុចរួមដូចគ្នានោះគឺថា គាត ឈន់ និង ហោ ណាំហុង គឺជាកម្មាភិបាលជាន់ខ្ពស់ពីររូបដែលស្ថិតនៅក្រោមជនជាប់ចោទផ្ទាល់ ដោយ*បានដឹងដោយផ្ទាល់* អំពីរចនាសម្ព័ន្ធបញ្ជារវាងមជ្ឈិមបក្សខាងលើខ្លួនជាមួយនឹងខ្លួន និងជាមួយនឹងកម្មាភិបាលថ្នាក់ក្រោមៗខ្លួន។ សក្ខីកម្មទាំងឡាយណា ដែល

---

[១១] ឯកសារ **D-427**, 'ដីកាដំណោះស្រាយ', ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ERN 00604508-00605246 ('ដីកាដំណោះស្រាយ'), កថាខណ្ឌ ៣៤ (សមាជិកត្រូវធ្វើសេចក្តីសម្រេចរួមជាមួយសមាជិកផ្សេងទៀត; ការបែងចែកឱ្យទទួលខុសត្រូវក្នុងគណៈកម្មាធិការកណ្តាលអចិន្ត្រៃយ៍ តែចំពោះការងារ 'តាមផ្នែកជាក់លាក់' ប៉ុណ្ណោះ), ៨៩៣-៨៩៤ (ចោទថា នួន ជា បានរស់នៅ និងធ្វើកិច្ចការប្រចាំថ្ងៃជាមួយ អៀង សារី ស្ទើរតែពេញមួយរយៈពេលនៃរបបនេះ), ៩៤៨ (ចោទថា នួន ជា 'បានដើរតួនាទីក្នុងការចាប់ខ្លួនកម្មាភិបាលនៅក្នុងក្រសួងដទៃទៀត ជាពិសេសនៅក្នុងក្រសួងការបរទេស')។

[១២] ឯកសារ **E-1/55.1**, 'កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី', ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, ERN 00796319-00796427, ទំព័រ ៧៧:៨ ដល់ ១៦; មើលផងដែរ *ដូចខាងលើ*, ទំព័រ ៦៩:១ ដល់ ៩ (ប៉ង់ ជាអ្នក "គ្រប់គ្រងរួម" នៅស២១" ក្រោមការណែនាំផ្ទាល់របស់ ប៉ុល ពត)។

[១៣] ញត្តិគាំទ្រ, កថាខណ្ឌ ៣ (ដកស្រង់ចេញពីដីកាដំណោះស្រាយ កថាខណ្ឌ ១១០១ (ដែលចោទថា បឹងត្របែក 'ត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ង់ ដែលត្រូវរាយការណ៍ទៅ នួន ជា ដែលជាអ្នកទទួលខុសត្រូវរួមលើការរៀនសូត្រ និងបំពាក់បំប៉ន')។

រៀបរាប់អំពីភាពស្វយ័ត ឬ អំណាច ចំណាងទាក់ទងដោយផ្ទាល់រវាងកម្មាភិបាលក្រោមបង្គាប់ជនជាប់ចោទ និង ប៉ុល ពត ឬ ដែនកំណត់នៃទំនាក់ទំនងថ្នាក់លើៗជាមួយនឹងមជ្ឈិមបក្ស គឺពាក់ព័ន្ធ។ ជាងនេះទៅទៀត វាជាជំហររបស់ក្រុមមេធាវីការពារក្តី ដែលស្វ័យភាព និងសេរីភាព នៃសកម្មភាពរបស់កម្មាភិបាលថ្នាក់ក្រោម (ដូចជា លោក ហោ ណាំហុង, និងលោក គាត ឈន់) មានវិសាលភាពធំធេងជាង បើយើងមើលនូវអ្វីដែលមានផ្ទុះបញ្ចាំងក្នុងដីកាដំណោះស្រាយ និងសូមលើកឡើងថាការផ្តល់នូវសក្ខីកម្ម(ដោយស្មោះត្រង់) របស់បុគ្គលដែលពាក់ព័ន្ធដោយផ្ទាល់ នឹងឆ្លុះបញ្ចាំងឲ្យឃើញពីរឿងនេះ។ សក្ខីកម្មរបស់ពួកគេ នឹងច្បាស់ជាអាចដោះបន្ទុក ខណៈដែលសក្ខីកម្មនោះអាច(ជាជំនួយក្នុង) ការបន្ធូរបន្ថយ ឬដកចេញនូវការដាក់បន្ទុកមកលើរូបលោក នួន ជា ដែលទទួលពីអំពើដែលបានប្រព្រឹត្តដោយកម្មាភិបាលថ្នាក់ក្រោម។ សាក្សីដែលបានធ្វើប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹង នួន ជា ក៏ពុំសូវសម្បូរ ហើយកិច្ចខិតខំរបស់ក្រុមមេធាវីការពារក្តីក្នុងការជម្រុញឲ្យអង្គជំនុំជម្រះស្តាប់សាក្សីទាំងនេះ (ដូចជា ករណី ហេង សំរិន និងជា ស៊ីម) ក៏ពុំទទួលបានជោគជ័យដូចគ្នាដែររហូតមកដល់ពេលនេះ។ កង្វះសក្ខីកម្មប្រភេទនេះ ក៏បានឆ្លុះបញ្ចាំងឲ្យ យើងឃើញផងដែរថា ភស្តុតាងអំពីរចនាសម្ព័ន្ធបញ្ជាថ្នាក់លើៗ កន្លងមកចេញមកពីការភស្តុតាងឯកសារ ជាជាងបទពិសោធន៍ផ្ទាល់ខ្លួន មិនថាសាក្សីទាំងនោះជាអ្នកជំនាញ ឬ សាក្សីដែលបានមកផ្តល់សក្ខីកម្មផ្ទាល់លើអង្គហេតុនេះទេ[១៤]។

៧. ចំណុចទីពីរ ស.ព.អ បានច្រានចោលសំណើរបស់ក្រុមមេធាវីការពារក្តីថា *បន្ថែមលើ* តម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់សាក្សីទាំងពីររូបនេះ ការបដិសេធរបស់សាក្សីនាពេលមុនមិនព្រមគោរពតាមដីកាកោះដែលបានចេញតាមផ្លូវច្បាប់ គឺជាចំណុចពាក់ព័ន្ធមួយទៅនឹងបញ្ហាថាតើគួរកោះហៅបុគ្គលទាំងពីរនេះមកផ្តល់សក្ខីកម្មឬក៏អត់ បានកត់សម្គាល់ថា "ការជ្រៀតជ្រែកខាងនយោបាយ" មិនមែន

[១៤] ទាក់ទងនឹងករណី ឌុច, *មើលឧទាហរណ៍*, ឯកសារ E-1/61.1, 'កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី', ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២, ERN 00800388-00800514, ទំព័រ ១:២៤ ដល់ ២:៩ (ក្នុងអំឡុងរបបនេះ មុខងារ ការដឹងឮ និងការបំលាស់ទីត្រូវបានរិតត្បិតត្រឹមតែ ស២១ ប៉ុណ្ណោះ); ឯកសារ **E1-51.1**, 'កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី', ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២, ERN 00792960-00793045, ទំព័រ ៤២:៩ ដល់ ៤៣:១៤ (ស្រដៀងគ្នានេះដែរ); ឯកសារ **E1-60.1**, 'កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី', ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១២, ERN 00799802-00799922, ទំព័រ ៦៧:២ ដល់ ២០, ៧៣:១ ដល់២១, ៨២:២៤ ដល់ ៨៣:២៥។

ជាបទចោទមួយនៅក្នុងដីកាដំណោះស្រាយដែលប្រឆាំងនឹងលោក នួន ជា ឡើយ [...]”[១៥]។ ដោយរៀបរាប់ក្នុងលក្ខណៈលេង សើចមិនសំខាន់ដូច្នេះ ការលើកឡើងបែបនេះធ្វើយ៉ាងមានការព្រួយបារម្ភ ។ វាបានបង្ហាញច្បាស់ថា ស.ព.អ បដិសេធមិនទទួលស្គាល់ថា ការជំនុំជម្រះ ពុំគួរកម្រិតត្រឹមតែលើការបង្ហាញពីការគាំទ្រ ឬមិនគាំទ្រកថាខណ្ឌទាំងឡាយនៅក្នុងដីកាដំណោះស្រាយនោះទេ។ ការពិចារណាការជំនុំជម្រះដ៏ត្រឹមត្រូវ គឺជាចំណុចសំខាន់ជាចាំបាច់នៃការជំនុំជម្រះ (ដ៏ត្រឹមត្រូវមួយ) ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ពេញលេញក្នុងពេលសវនាការ ហើយគួរទទួលយកពិចារណានៅក្នុងសវនាការជាសាធារណៈរបស់អង្គជំនុំជម្រះ ជាពិសេស នៅ អ.វ.ត.ក នេះតែម្តង ដែលការទទួលខុសត្រូវមួយផ្នែករបស់អ្នកវិជ្ជាជីវៈច្បាប់អន្តរជាតិនៅទីនេះ គឺដើម្បីជួយភាគីជាតិ និងជូនដំណឹងដល់សាធារណជនអំពីបទដ្ឋាននៃការជំនុំជម្រះក្តីដោយ យុត្តិធម៌។ ចំណុចនេះទំនងជាមិនមែនជាការគិតគូរសំខាន់របស់ ស.ព.អ ឡើយ ដែលបិទបាំងដោយប្រើពាក្យលេងសើច “មិនសំខាន់” ទៅវិញ។

៨. ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្តីពុំប្រាកដសោះថាតើ ស.ព.អ យល់ដឹងពេញលេញអំពីភាពផ្ទុយគ្នាយ៉ាងខ្លាំងនៃការប្រឹងលើកយោងរបស់គាត់ទៅវិធាន ៣៥ នៃវិធានផ្ទៃក្នុង[១៦] នៅក្នុងបរិបទនេះពោលគឺ បញ្ហា *ជាក់លាក់* នៃការមិនព្រមចូលខ្លួនរបស់ ហោ ណាំហុង និង គាត ឈន់ *គឺជា* កម្មវត្ថុនៃពាក្យសុំអនុលោម តាមវិធាន ៣៥ របស់ក្រុមមេធាវីការពារក្តី ដែលនាំឱ្យ អ.ប.ជ ចេញសេចក្តីសម្រេចខ្វែងយោបល់គ្នាដ៏អសោធមួយ ដែលនៅក្នុងសេចក្តីសម្រេចនេះ ចៅក្រមជាតិបានអនុវត្តយ៉ាងច្បាស់ និងអាចព្យាករណ៍ជាមុន ទៅតាមគោលនយោបាយបក្សប្រជាជនកម្ពុជាចំពោះបញ្ហានេះ ជាហេតុនាំឱ្យមានការច្រានចោលសំណើសុំ របស់ក្រុមមេធាវីការពារក្តីយើងខ្ញុំធ្វើឡើងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[១៧]។ បទពិសោធន៍នោះបានបង្ហាញច្បាស់អំពី *ភាពគ្មានប្រយោជន៍* នៃវិធាន ៣៥

---

[១៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨។

[១៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨។

[១៧] ពិតណាស់ ចៅក្រមបរទេសបានសន្និដ្ឋានថា “គ្មានអង្គហេតុសមរម្យ” អាចធ្វើឱ្យខកខានក្នុងការពិចារណាដែលថា “មានហេតុផលមួយដែលគួរឱ្យជឿបានថា សមាជិកម្នាក់ ឬច្រើននៃរដ្ឋាភិបាលអាចដឹង ឬមានបំនងជ្រែតជ្រែកមកលើសាក្សី” ចង់ចូលអន្តរាគមន៍ជាសាក្សីនោះទេ)ឯកសារ **D-314/1/12**, ‘សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និងលោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី’, ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ERN 00600748-00600774។

នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងពាក្យសុំលើបញ្ហានៃការជ្រៀតជ្រែក*ខាងនយោបាយ*។ ការលាក់បិទបាំងនៅពី ក្រោយវិធាននេះ គឺជាការបិទភ្នែកដោយចេតនាលើភាពជាក់ស្តែងនៅ អ.វ.ត.ក និងនៅក្នុងសង្គមកម្ពុជា ទូទៅ[១៨]។

៩. ចំណុចទីបី ស.ព.អ ផ្តល់ទឡ្ហីករណ៍ថា បទដ្ឋានសម្រាប់ការទទួលយកភស្តុតាង អនុលោតាមវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង អាចមិនត្រូវបានបំពេញឡើយនៅក្នុងករណីនេះ និងថា ហេតុដូច្នេះហើយ ស.ព.អ អាចជំទាស់យ៉ាងសមស្របទៅនឹងការទទួលយកសក្ខីកម្មរបស់សាក្សី ដោយពុំចាំបាច់លើកអំពីភាពពុំស៊ីសង្វាក់គ្នាជាមួយនឹងជំហររបស់ ស.ព.អ ក្នុងដំណាក់កាលស៊ើបសួរ ដែលថាសាក្សីទាំងពីរដដែលនេះគួរត្រូវបានបង្ខំឱ្យចូលខ្លួន[១៩]។ យោងតាមការលើកឡើងនៅក្នុងចម្លើយតបដើមដំបូង ស.ព.អ៖

---

[១៨] សូមមើល “Tell them that I want to kill Them” Two decades of Impunity in Hun sen s Cambodia, របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ឆ្នាំ ២០១២ ទំព័រ ១២៖ តុលាការ និងប្រព័ន្ធយុត្តិធម៌ត្រូវបានគ្រប់គ្រងដោយ ហ៊ុន សែន និង គណបក្សប្រជាជនកម្ពុជា។ ចៅក្រម និងព្រះរាជអាជ្ញាភាគច្រើន ជាសមាជិក គណបក្សប្រជាជន កម្ពុជា ដែលអនុវត្តទិសដៅរបស់បក្សហើយពួកគេជឿថាពួកគេគ្មានផ្លូវផ្សេងណាដើម្បីធ្វើផ្ទុយពីទិសដៅបក្សឡើយ។ ត្រង់ទំព័រ ៦៤ “ប្រព័ន្ធយុត្តិធម៌ នៅតែជា ស្ថាប័នពាក់ព័ន្ធជ្រៅ និងមិនដាច់ស្រឡះខាងនយោបាយ ជាមួយនិង មន្ត្រីជាន់ខ្ពស់ជាច្រើនដែលជាបេក្ខជនតែងតាំងដោយនយោបាយ ហើយមានស្វាមីភក្តិចំពោះនាយករដ្ឋមន្ត្រី និងគណបក្សប្រជាជនដែលគ្រប់គ្រងអំណាច”។

[១៩] មេធាវីការពារក្តីសូមបញ្ជាក់ថា ញត្តិគាំទ្រនោះមិនបានរិះគន់ដល់ការខកខានរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការស្នើឱ្យធ្វើការបង្ខំសាក្សីដើម្បីចូលមកផ្តល់សក្ខីកម្មនោះទេ ប៉ុន្តែរិះគន់ចំពោះការខកខានក្នុងការបំពេញការងារនៅក្នុងដំណាក់កាលនេះ។ ញត្តិនេះបានរិះគន់សហព្រះរាជអាជ្ញាអន្តរជាតិដែលបានបញ្ជាក់ដោយប្រយោលថា គាត់ *ធ្វើការអះអាងជំទាស់ទៅនឹងសក្ខីកម្មនេះ* ដោយប្រើប្រាស់ជំហររបស់គាត់ពីមុនថាជាចំណុចបង្ហាញដែលមានលក្ខណៈផ្ទុយគ្នា។ ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ‘វាគ្មានអ្វីត្រូវភ្ញាក់ផ្អើលទេថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងព្យាយាមបង្ខំឱ្យសាក្សីត្រូវតែមកផ្តល់សក្ខីកម្ម’ គឺជាសេចក្តីសន្និដ្ឋានមិនពាក់ព័ន្ធគួរឱ្យចង់សើច, មើលចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១៤។ ការសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិដោយផ្អែកលើមូលហេតុស្រដៀងគ្នាដែលថា នៅខែមីនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានធ្វើកោះហៅសាក្សីទាំងនេះរួចហើយនោះ ពុំមានភាពពាក់ព័ន្ធឡើយ។ មើលចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១៣។ មេធាវីការពារក្តីមិនធ្វើការទាមទារចំពោះអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិគួរធ្វើ *ចាប់ពីពេលនេះតទៅនោះទេ* ប៉ុន្តែផ្ទុយទៅវិញ សហព្រះរាជអាជ្ញាគួរធ្វើអ្វីខ្លះនៅពេលដែលអង្គជំនុំជម្រះខកខានក្នុងការធានាឱ្យសាក្សីចូលខ្លួន។ មេធាវីការពារក្តីក៏មិនបានស្នើថា ក្នុងករណីបែបនេះ សហព្រះរាជអាជ្ញាអន្តរជាតិគួរគាំទ្រការស្នើសុំព្យាយាមឱ្យបង្ខំសាក្សីមកផ្តល់សក្ខីកម្មផងដែរ។(ការអង្កេតរបស់ ICP ដែលនៅក្នុងខែមីនា ២០១០ សាក្សីជាច្រើនដែលត្រូវបានកោះហៅដោយ សហព្រះរាជអាជ្ញា គឺទំនងជា មិនពាក់ព័ន្ធ ខណៈដែលមេធាវីការពារក្តី

បានបង្ហាញច្បាស់លាស់អំពីការមន្ទិលសង្ស័យរបស់ខ្លួនថា វិធាន ៨៧(៣) ត្រូវបានបំពេញសព្វគ្រប់...ដែលបញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានជឿថា សក្ខីកម្មរបស់ គាត ឈន់ និង ហោ ណាំហុង "មានសារៈសំខាន់ស្លាប់រស់" ឬមួយមិន "ចំបាច់តម្រូវឲ្យមានទេ ដើម្បីគោរពដល់សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ អៀង សារី" ហើយរក្សាមតិថាតើសក្ខីកម្មរបស់ពួកគេត្រូវបាន ឬ អាចនឹងត្រូវបដិសេធអនុលោមតាមវិធានផ្ទៃក្នុង ឬមួយនាំទៅរកការពិត ដែរ ឬទេ?[២០]

១០. ការលើកឡើងដូច្នេះ អាចចាត់ទុកថាជាការបំភ្លៃការពិត ដែលមានចេតនាធ្វើឲ្យមានភាពច្របូកច្របល់។ តាមការពិត ចម្លើយតបដំបូងរបស់ ស.ព.អ ពុំបានបង្ហាញ "ភាពសង្ស័យ" អ្វីទាំងអស់ អំពីថា វិធាន ៨៧(៣) *ត្រូវបានបំពេញ* ដោយ *គ្រាន់តែ* លើកឡើងថា នៅក្នុងពេលបច្ចុប្បន្ន លោក "ពុំជំទាស់" សំណើសុំនេះ ហើយ លោក (i) *អាច* (ii) ជំទាស់នាពេលខាងមុខណាមួយ។ មូលដ្ឋានតែមួយគត់ដែលលោកបានបង្ហាញនៅក្នុងការឆ្លើយតបដំបូងរបស់គាត់ ចំពោះការជំទាស់នេះ គឺពាក់ព័ន្ធនឹងលទ្ធភាពដែលថា "ការព្យាយាមក្នុងពេលអនាគតដើម្បីឲ្យទទួលបានសក្ខីកម្មទាំងនោះ នឹងនាំឲ្យមានការពន្យារពេលយ៉ាងច្រើន ឬថាភស្តុតាងនោះអាចបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាមិនអាចទទួលបានឡើយ"[២១]។ ស.ព.អ ពុំបាន (នៅតែពុំបាន) ស្នើឡើងថា សក្ខីកម្មនេះអាចពុំមានការពាក់ព័ន្ធ អនុលោមតាមវិធាន ៨៧(៣)(ក) ឬ ខកខានមិនបានបំពេញតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

---

មិនបានធ្វើការអះអាងណាមួយអំពីការដែលថា ICP គួរតែស្វែងរកការកំណត់ ព្រំដែនសាក្សីទាំងនោះ។ សូមមើល ចម្លើយតបរបស់ ICP កថាខណ្ឌ១៣ , ក្នុងករណីណាក៏ ICP បានសញ្ជឹងគិតយ៉ាងយកចិត្តទុកដាក់ ដើម្បីជំទាស់ក្នុងពេលដែលអង្គជំនុំជម្រះ បានព្យាយាម និងបរាជ័យក្នុងការធានាការពារនូវសក្ខីកម្ម ដូច្នេះសន្មត់ថានៅតែមានការកោះហៅ។

[២០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២។ កថាខណ្ឌ១៤ (អះអាងថានៅក្នុងចម្លើយតបលើកដំបូងគាត់បានបញ្ជាក់ដោយត្រង់ថា គាត់មិនគិតថា សក្ខីកម្មមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីចោទប្រកាន់ចំពោះ អៀង សារី។)

[២១] ចម្លើយតបដំបូងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៤ ('វាអាចធ្វើបាន (តែមិនប្រាកដ) ថា ការព្យាយាមក្នុងពេលអនាគតដើម្បីឲ្យទទួលសក្ខីកម្មទាំងនេះ ជាលទ្ធផលគឺនឹងនាំឲ្យមានការពន្យារពេលយ៉ាងច្រើន ឬក៏ថា ភស្តុតាងនោះអាចបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា មិនអាចទទួលបានឡើយ ...។ ការអភិវឌ្ឍដូច្នេះអាចមានឥទ្ធិពលជាយថាហេតុ ដែលអនុគ្រោះដល់ការកំណត់សម្រេចថា ភស្តុតាងដែលបានស្នើឡើងគួរតែបានច្រានចោល អនុលោមតាមវិធាន ៨៧(៣)(ខ) នៃវិធានផ្ទៃក្នុង ពីព្រោះតែមិនអាចទទួលបាននៅក្នុងរយៈពេលសមស្របណាមួយ។ *ដោយសារមូលហេតុនេះ និងនៅក្នុងខណៈពេលបច្ចុប្បន្ន ដែលមិនមានការជំទាស់នឹងសំណើរបស់មេធាវីការពារក្តីនោះ* សហព្រះរាជអាជ្ញាអន្តរជាតិសូមរក្សាសិទ្ធិដើម្បីដាក់សេចក្តីសន្និដ្ឋានបន្ថែមទៀត នៅថ្ងៃក្រោយទាក់ទងអំពីថា តើសក្ខីកម្មដែលបានស្នើឡើងគួរតែច្រានចោល ឬអត់')។

ដែលទាមទារឲ្យភស្តុតាងថ្មីត្រូវ "នាំទៅដល់ការបញ្ជាក់ការពិត"។ ជាការពិត ស.ព.អ បានទទួលស្គាល់យ៉ាងច្បាស់ ថា សំណើសុំរបស់ អៀង សារី "បានដាក់វាដោយមានការពិពណ៌នាមួយយ៉ាងគ្រប់គ្រាន់អំពីការ អះអាងថាវាមានតម្លៃជាភស្តុតាង ទាក់ទងទៅនឹង អៀង សារី ដែរ"[២២]។ ចំណុចពិចារណាផ្សេង ទៀត ដែលត្រូវបានលើកឡើងដោយ ស.ព.អ ថាតើសក្ខីកម្មនេះ "មានសារៈសំខាន់ស្លាប់រស់" ឬត្រូវការ "ដើម្បីគោរពដល់សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ អៀង សារី" មិនមានភាពពាក់ព័ន្ធទៅនឹងបទដ្ឋានអនុវត្តជាធរមាន ដែល ដូច ស.ព.អ ទទួលស្គាល់ថា[២៣] វាទាក់ទងថាតើភស្តុតាងទាំងនេះ "នាំទៅដល់ការបញ្ជាក់ការពិតដែរឬទេ"។ ទោះបីជាមានការបង្វែរការយល់ឃើញទាំងនេះយ៉ាងណាក៏ដោយក្តី វានៅតែបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ថា *ហេតុផល*តែមួយគត់ ដែលវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង ខកខានមិនត្រូវបានបំពេញនាពេលអនាគត គឺថា សាក្សី នឹងខកខានមិនមកបង្ហាញខ្លួនដោយខុសច្បាប់។ ដូចក្រុមមេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍ពីដំបូង[២៤] ពុំមានមូលដ្ឋានស្របច្បាប់ក្នុងការដកភស្តុតាងនេះចេញឡើយ។

១១. ចំណុចចុងក្រោយ ស.ព.អ បានអះអាងថា "ហាក់ដូចជាលើកមកជជែកតវ៉ាថា ហោ ណាំហុង និង គាត ឈន់ គួរតែត្រូវបានធ្វើការកោះហៅ ព្រោះមកពីលក្ខណៈខាងក្រៅបង្ហាញថា *ជានិមិត្តរូប* ច្រើនជាងភស្តុតាងជាតម្លៃនៃបណ្តឹងនោះ"[២៥]។ ទោះបីជាបានអះអាងដោយពុំត្រឹមត្រូវបែបនេះក៏ដោយក្តី (សូមមើលកថាខណ្ឌ ៤-៦ *ខាងលើ*) សេចក្តីអង្កេតរបស់ ស.ព.អ ពិតជាបានលើកឡើងពីបញ្ហាសំខាន់មួយ គឺ និមិត្តរូប។ នៅក្នុងប្រទេសដូចកម្ពុជានេះ ដែលនិទណ្ឌភាព និងកង្វះការទទួលខុសត្រូវ

[២២] ចម្លើយតបដំបូងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, ជើងទំព័រ ២។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានបញ្ជាក់ថា បញ្ហាដែលបានកើតមាននៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបសួរគឺថាតើសក្ខីកម្មនៅពេលខាងមុខជាប់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរឬទេ ផ្ទុយទៅវិញបញ្ហាក្នុងអំឡុងពេលនៃដំណាក់កាលជំនុំជម្រះគឺថាតើសក្ខីកម្មនោះមានជាប់ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយដែរឬទេ។ *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១១។ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានព្យាយាមបង្ហាញឲ្យតើមានមូលដ្ឋានអ្វីដែលសហព្រះរាជអាជ្ញាមាន - ឬ អាចមាន ផ្អែកតាមការវិភាគរបស់ខ្លួននោះក្រោយពីបានពិចារណាលើអង្គហេតុថា ស្ថាប័នពាក់ព័ន្ធ និងវចនាសម្ព័ន្ធបញ្ជាគឺជាផ្នែកយ៉ាងសំខាន់នៅក្នុងឯកសារទាំងពីរនេះ។ ទោះក្នុងករណីណាក៏ដោយ ដូចបានធ្វើការកត់សម្គាល់នៅទីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានឯកភាពរួចហើយថា សក្ខីកម្មនេះមានជាប់ពាក់ព័ន្ធ។

[២៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨។

[២៤] ញត្តិគាំទ្រ, កថាខណ្ឌ ៦។

[២៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៨។

របស់មន្ត្រីរដ្ឋាភិបាលនៅចំពោះមុខតុលាការ គឺជាបញ្ហាព្រួយបារម្ភចំបងនោះ[២៦] តម្លៃនៃនិមិត្តរូបនេះ គឺឃើញមាននៅទីនេះ*ពិតប្រាកដមែន*។ ការផ្តល់ការគាំទ្រដោយបង្ខំពីខាង ស.ព.អ លើបញ្ហាកោះហៅមន្ត្រីជាន់ខ្ពស់នៅក្នុងគណបក្សប្រជាជនកម្ពុជា ដែលបានមិនគោរពដោយគឃ្លើនចំពោះដីកាកោះហៅតាមផ្លូវច្បាប់នាពេលមុនៗ អាចមិនបានដល់ "និមិត្តរូប" នោះផង ប៉ុន្តែ វានឹងធ្វើឲ្យមានការផ្លាស់ប្តូរសំខាន់សម្រាប់ការអភិវឌ្ឍនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត ការព្រមទទួលយកស្ថានភាពបច្ចុប្បន្នពីខាង ស.ព.អ យ៉ាងស្ងាត់ដូច្នេះ បង្កើតជានិមិត្តរូបមួយទៀត ដែលជួយជាប្រយោជន៍កាន់តែតិចទៅទៀត។

**សហមេធាវីការពារក្តី នួន ជា**

Michiel PESTMAN Andrew IANUZZI Jasper PAUW

[២៦] សូមមើលរបាយការណ៍ឃ្លាំមើលសិទ្ធិមនុស្ស ទំព័រ ៥ ("មន្ត្រីជាន់ខ្ពស់ គឺមិនដែលទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ"), ទំព័រ៦៤ (នៅដើមឆ្នាំ១៩៩៥ អ្នកតំណាង ពិសេសរបស់អង្គការសហប្រជាជាតិ Michael Kirby បានផ្តល់អនុសាសន៍ថាគណកម្មការអន្តរស្ថាប័នជាន់ខ្ពស់គួរត្រូវបានបង្កើតឡើង ដើម្បីស៊ើបអង្កេត និងរាយការណ៍ អំពីការតវ៉ាតាមផ្លូវច្បាប់ ដែលពាក់ព័ន្ធនឹងការបដិសេធ ឬការខកខានរបស់ យោធា នគរបាល ឬមន្ត្រីនានាក្នុងការអនុវត្តដីការបស់តុលាការដែលមាន អានុភាពចំពោះក្រុមគ្រួសាររបស់ពួកគេ។ ពីរឆ្នាំក្រោយមកទៀត គ្មានការវិវត្តណាមួយទេដែលជាភស្តុតាង ហើយអ្នកស្នងតំណែង របស់លោក គឺលោកThomas Hammarberg ត្រូវបានគេកោះហៅឲ្យដើម្បីជាប្រយោជន៍នៃការកំណត់សកម្មភាពនានា ដែលអាចបង្ហាញឲ្យឃើញពីនិទណ្ឌភាព។ អ្នកបន្ទាប់ពី លោក Hammarberg ក៏បានទទួលការកោះហៅដូចគ្នាដែរ។ ទោះជាមិនបានជោគជ័យក៏ដោយ ក៏ ហ៊ុន សែន ជារឿយៗបានតបត និងការចោទប្រកាន់នេះដោយការវាយប្រហារប្រកបដោយកំហឹង ចំពោះអាកប្បកិរិយារបស់ពួកគេ។